និពន្ធដោយ

លឹម សន្តិភាព

# ក្លឹប
# អ្នកស៊ើបអង្កេត



សមាគមសេរីភាព
LIBERTY ASSOCIATION

រឿង

# ក្លឹបអ្នកស៊ើបអង្កេត

និពន្ធដោយ

## លឹម សន្តិភាព

គ្រប់មាតិកានៃរឿងនេះជាកម្មសិទ្ធិបញ្ញា
របស់ អ្នកស្រី **លឹម សន្តិភាព**។

នេះគឺជាសៀវភៅរឿងប្រលោមលោកបែបច្នៃប្រឌិត។ ឈ្មោះតួអង្គ
ទីកន្លែង និង ហេតុការណ៍តួអង្គនៅក្នុងសៀវភៅនេះ
សុទ្ធតែជាការស្រមើស្រមៃ។

រាល់ព្រឹត្តិការណ៍ ដែលស្រដៀង រឺដូចគ្នាទៅនឹងភាពជាក់ស្តែង
បុគ្គល (នៅរស់ រឺស្លាប់) និងទីកន្លែង រឺស្ថាប័ន
គឺជាការចៃដន្យតែប៉ុណ្ណោះ។

## វគ្គទី ១

ករុណាកាន់សំពៀតនៅនឹងដៃ ចូលទៅកាន់សាលារៀន។ នាងងើយ ក សំលឹងទៅ មើលផ្លាកសាលារៀនថ្មីរបស់នាង ដែលសរសេរថា "ហៃរ្យនម៉ា"។ ករុណាមានអារម្មណ៍ មិនស្រួលក្នុងចិត្តសោះ ព្រោះតែល្បីថា សាលានេះ សំបូរទៅដោយកូនៗ របស់មន្ត្រីជាន់ខ្ពស់ របស់អ្នកមាន ជាច្រើននាក់ នៅទីក្រុងភ្នំពេញ។ សិស្សភាគច្រើនមានចារិក មិនល្អ មិនចេះស្តាប់គ្រូ មិនខ្វល់ពីអ្នកដទៃ អាត្មានិយម ដោយសារតែអាងថា ខ្លួនជា កូនរបស់អ្នកមានអំណាច អ្នកមានឥទ្ធិពល នៅប្រទេសកម្ពុជា។

បើគ្រួសាររបស់ករុណាមិនមែនជាគ្រួសារអ្នកមាន ហើយក៏មិនមែនជាគ្រួសារ អ្នកមានអំណាចអ្វីផង ម៉េចក៏នាងមានប្រាក់បង់ចូលរៀនសាលាដ៏ថ្លៃនេះបាន?

ករុណាលើកដៃឆ្វេងឡើងលើ ប្ដេជ្ញា : "មានរឿងអ្វី ក៏មានទៅ ត្រូវតែក្លាហានឡើង ករុណា!"។

បន្ទាប់ពីប្ដេជ្ញាចិត្តរួច នាងក៏ឈានជើងចូលរបងសាលា ស្រាប់តែមានសំលេង ខ្ទោកនៅលើដី។ករុណាបើកភ្នែកធំៗ ហើយមានសំរែក របស់សិស្សស្រីផ្សេងទៀតយ៉ាងខ្លាំង។ នៅពីក្រោមជើងរបស់ករុណា មានរបស់អ្វីម្យ៉ាងរឹង ហើយរាងជាបន្ទះ។ នៅចំពោះមុខរបស់នាង មានសិស្សស្រីម្នាក់រូបរាងស្អាតបាតសក់រួញបន្តិច មើលទៅ ស្រស់ខ្លាំងណាស់។ នាងមានឈ្មោះថានីតា។

- នីតា : ឯង .... ឯង ធ្វើបែករបស់ខ្ញុំហើយ។ ឯងត្រូវតែសងខ្ញុំភ្លាម។

ករុណាសំលឹងមើលទៅក្រោមបាតជើងរបស់នាង ឃើញមានប្រអប់ម៉ាគីយេមួយ មានផ្លាកយីហោថា ឆាណែល។ វាជាម៉ាកល្បីទូទាំងសកលលោក ហើយភាគច្រើនជា របស់ប្រើប្រាស់របស់កូនអ្នកមានផង។ នាងគិតថា ហេតុតែជាកូនស្រីអ្នកមាន ក៏យករបស់ថ្លៃយ៉ាងនេះដាក់តាមខ្លួន។ ករុណា អោនលើកប្រអប់

ម៉ាគីយេឡើង ក៏ឃើញថា បែកមែន។ នាងបោសដីជាប់លើប្រអប់ម៉ាកគីយេនោះបន្តិច ហើយហុចអោយនីតាវិញ។

- ករុណា : របស់ឯងរឺ? ណេះយកវិញទៅ។
- នីតា : ទេ... ពេលនេះ វាខូចហើយ ឯងជាអ្នកធ្វើអោយវាខូច ឯងត្រូវតែ សងរបស់ថ្មីមកយើងវិញភ្លាម។
- ករុណា : ខ្ញុំមិនមែនជាអ្នកធ្វើអោយប្រអប់របស់នេះបែកទេ មានរឿងអ្វី ខ្ញុំត្រូវសងរបស់ថ្មីដល់ឯង។ បើឯងមិនចង់បានវាទេ បោះវាចោលទៅ។

ករុណាដាក់ប្រអប់ម៉ាគីយេចុះទៅលើដីវិញ ហើយដើរចេញទៅ។ នីតាទាញ ដៃអាវរបស់ករុណា។

- នីតា : ឈប់សិន ឯងចង់រត់ទៅណា។ ចង់គេចរួចខ្លួនរឺ? មិនងាយស្រួល យ៉ាងនេះទេ?

ករុណាបែរមកមើលនីតាវិញ។

- ករុណា : បាន បើឯងចង់បានរបស់ថ្មី ទៅប្តឹងនាយកសាលាទៅ!
- នីតា : ស្មានតែយើងខ្លាច រឺ? ម៉ោះទៅបន្ទប់នាយកសាលាទាំងអស់គ្នា!

បន្តិចក្រោយមក ករុណា និងនីតានៅក្នុងបន្ទប់នាយកសាលា។ នីតា បានរៀបរាប់ តាមដំណើររឿង។ ស្តាប់ចប់ហើយនាយកសាលាមើលមក ករុណា ចង់ដឹងថា នាងនឹង និយាយថាម៉េចវិញ។

- ករុណា : ប្រអប់ម៉ាគីយេនេះ ពិតជាត្រូវគេជាន់អោយបែកមែន ប៉ុន្តែមិន មែនជារូបខ្ញុំទេ។
- នីតា : នៅក្រោមជើងរបស់ឯង បើមិនមែនជាន់ដោយសារឯង តើនរណា ជាន់?

ករុណាកាន់ប្រអប់ម៉ាគីយេ ហើយបង្ហាញទៅនាយកសាលា។ នៅដៃម្ខាងរបស់នាង នាងកាន់ស្បែកជើងម្ខាងរបស់នាង។

- ករុណា ៖ ប្រអប់នេះ បែកដោយសារតែស្បែកជើងខ្ពស់ រឺក៏ហៅថា ស្បែកជើងកែងចោទជាន់ពីលើ ព្រោះវាមានស្នាមទំលុះពីលើដល់បាតរបស់វា។
  មើលបាតស្បែកជើងរបស់ខ្ញុំ ទៅមើល គឺ រាបស្មើ តើវាម៉េចនឹងអាច ធ្វើអោយមានស្នាមធ្លុះទៅបាន។

នាយកសាលាចាប់ប្រអប់ម៉ាគីយេកាន់មើល ក៏ឃើញថា ស្នាមធ្លុះនោះបណ្តាល មកពីរបស់ស្រួចចាក់ទំលុះ មិនអាចជាស្បែកជើងរាបស្មើ ដូចជារបស់ករុណា អាច ទំលុះបានទេ។ ណាយកសាលា និងករុណាសំលឹងមើលទៅស្បែកជើងរបស់នីតា។ នីតារអៀសខ្លួន នៅស្ងៀម លែងស្តី បានតែញឹម១ដាក់នាយកសាលា។

- ករុណា : ខ្ញុំដល់ម៉ោងចូលរៀនហើយ តើខ្ញុំសុំជំរាបលាលោកនាយកទៅ ចូលរៀន បានទេ?
- នាយកសាលា : ទៅចុះ! សុំទោសផងណា៎ រំខានថ្ងៃចូលរៀនដំបូងរបស់ឯង។

ករុណាដើរចេញពីបន្ទប់របស់នាយកសាលា ទុកអោយនាយកសាលា នៅនិយាយតទល់នឹងនីតាតែពីរនាក់។ ដើរបានពីរបីជំហានចេញពីបន្ទប់ នាយកសាលា ករុណាដក ដង្ហើមធំ "មិនទាន់បានចូលរៀនផង ក៏ចូលបន្ទប់នាយកសាលាទៅហើយ។ គិតទៅកូនអ្នកមាននេះ ពូកែសន្សំរឿងមែន"។

ករុណាដើរចូលទៅរកថ្នាក់រៀនរបស់នាង។ ពេលនាងចូលថ្នាក់រៀនភ្លាម ភ្នែក គ្រប់គូបាញ់មករកនាង។ នាងរឹងខ្លួនបន្តិច។

- ករុណា : សុំទោសលោកគ្រូ! ខ្ញុំមកយឺត។
- លោកគ្រូ: អូ៎ នេះជាករុណា។ មកយឺត ត្រូវតែពិន័យតាមច្បាប់របស់ សាលា។

- ករុណា : អឺ... ខ្ញុំសុំទោស...
- លោកគ្រូ : សិស្សទាំងអស់គ្នា ថាទៅមើល អ្នកមកយឺត ត្រូវតែពិន័យ មែនទេ?
- សិស្សក្នុងថ្នាក់ : មែនហើយ ត្រូវតែពិន័យ...
- លោកគ្រូ : ហាកណេះ ប្រញាប់ថើបលោកគ្រូភ្លាមមក!

លោកគ្រូហុចថ្ពាល់ទៅអោយករុណា ។ ករុណាបើកភ្នែកធំៗ...

- ករុណា : ថាម៉េច????????

សិស្សទាំងអស់នាំគ្នាសើចគិលឡើង ។

ដល់ម៉ោងចេញលេង ខ្ញុំកាន់ក្រដាសមួយសន្លឹកនៅនឹងដៃ ។ នៅលើក្រដាសនេះ មានរៀបរាប់ពីក្លឹបជាច្រើន ។ ក្រៅពីម៉ោងរៀននៅក្នុងថ្នាក់រៀន សិស្សអាចចូលរួម ទៅក្លឹបផ្សេងៗទៀត តាមចំណង់ចំណូលចិត្តរបស់ខ្លួនបានដោយសេរី ។

- ករុណា ៖ ក្លឹប? ហ៊ឺ... នៅសាលារៀនធម្មតា មិនដែលឃើញមាន បើកក្លឹប ស្អីផង។ នេះបានចំជាសាលារៀនសំរាប់កូនអ្នកមាន មែន។

ករុណាដើរសំលឹងរកមើលផ្លាកក្លឹបអ្នកកាសែត។ ប៉ុន្តែដូចជាមិនឃើញមាននោះទេ។ នាងសំលឹងមើលទៅក្លឹបគីមី។ ាំនសិស្សជាច្រើននាក់ កំពុងតែពិភាក្សាគ្នា ធ្វើពិសោធន៍លើអ្វីម្យ៉ាង។ មើលទៅគួរអោយសប្បាយម្យ៉ាងដែរ។ មានសំលេង ផ្ទូងផាំង... ផ្ទុះចុះឡើង នៅពេលសិស្សដាក់ជាតិគីមីអ្វីមួយចូលទៅក្នុងថូពិសោធន៍នោះ។ ករុណាឈានជើង ប្រុងនឹងចូលបន្ទប់នោះ ស្រាប់តែមានដៃមួយទាញនាងរឹប ហើយអូសនាងទៅយ៉ាងលឿន។ ករុណាមិនដឹងថា មានអ្វីកើតឡើងនោះទេ នាងមានតែទប់ខ្លួន រត់តាមគេទាំងមិនដឹងខ្លួន។ បន្តិចមក ក៏មកដល់មុខបន្ទប់មួយ។ ករុណា មើលទៅមុខសិស្សស្រី ដែលអូសដៃករុណារត់មកអំបាញ់មិញនេះ គឺគ្មាននរណាក្រៅពី កញ្ញា នីតា ដែលមានចេតនារករឿងនាងអំបាញ់មិញនេះទេ។

- ករុណា : ឯងគឺ....

ករុណាងឹកឆ្ងល់ក្នុងចិត្ត ហើយគិតថា នេះ នីតា ចង់រករឿងអ្វីនាងទៀតហើយ។ ប្រហែលជាមិនទាន់អស់ចិត្តនឹងរឿងនាងបកស្រាយពី ប្រអប់ម៉ាគីយេនេះទេដឹង។ នាង រឹតតែភ្ញាក់ផ្អើលទៅទៀត នៅពេលឃើញនីតាសើចស្វាញដាក់នាង។ នីតារុញករុណា ចូលក្នុងបន្ទប់ថ្នាក់រៀននោះ ហើយញញឹមពព្រាយ។

- នីតា : ស្វាគមន៍ការមកដល់ ក្លឹបអ្នកស៊ើបអង្កេត របស់យើង។
- ករុណា : ហ្អា...
- នីតា : ឯងពិតជាពូកែដូចជាគេល្បីមែន។
- ករុណា : បានន័យថាម៉េចហ្នឹង?
- នីតា : សាលារៀននេះ ថ្លៃខ្លាំងណាស់។ សិស្ស ដែលមិនអាច សូម្បីតែទិញ ឯកសណ្ឋានសាលាបានផង មានរឿងអ្វីមានលុយ បង់ចូលរៀននៅសាលានេះ បាននោះ។

នីតាពិតជានិយាយត្រូវមែន។ សំលៀកបំពាក់ ដែលខ្ញុំស្លៀកមកនេះ ជាឯកសណ្ឋានសាលាចាស់របស់ខ្ញុំ។

- នីតា : ខ្ញុំបានលឺថា ឆ្នាំនេះ សាលា ហៃ្សនម៉ា ផ្តល់អាហារូបករណ៍ អោយសិស្សប៉ុន្មាននាក់។ ខ្ញុំបានឆែកមើលប្រវត្តិរូបរបស់សិស្សទាំងអស់នោះ ហើយខ្ញុំដឹងថា ឯងជាសិស្សពូកែភាសាខ្មែរលេខ១ ហើយក៏ជាសិស្សពូកែគណិតលេខ៣។ ពិតជាមិនធម្មតារបស់គេមែន។

ករុណានឹកក្នុងចិត្ត "រួចចុះ កូនអ្នកមានអី ក៏មកចាប់អារម្មណ៍ រឿងរ៉ាវ របស់ អ្នកដទៃច្រើនម្ល៉េះ?"

- នីតា : អនាគតទៅ ឯងចង់ធ្វើជាមេធាវីដ៏ល្បីម្នាក់។ ខ្ញុំនិយាយត្រូវទេ?
- ករុណា : និយាយអស់ហើយ រឺនៅ?

- នីតា : ពេលនេះ ជាឱកាសល្អរបស់ឯងហើយ បានចូលមកក្លឹប របស់ពួកយើង គឺ ក្លឹបអ្នកស៊ើបអង្កេត ។
- ករុណា : ហ្ហ៎ា...
- នីតា : ក្លឹបរបស់ពួកយើងល្បីឈ្មោះគួរសមដែរ ។ ពួកយើង ធ្លាប់បាន ដោះស្រាយរឿងក្តីខ្លះជាមួយប៉ូលីសទៀតផង ។ ឯងធ្លាប់លឺរឿងនេះទេ?
- ករុណា : មិនដែលលឺទេ ។

ករុណានិយាយផង គ្រវីក្បាលផង ។ នីតាធ្វើមុខដូចជាត្រូវគេខោកមួយក្រញ៉ូ ។

- ករុណា : ខ្ញុំទៅវិញហើយ ។
- នីតា : ឈប់សិន ។

នីតាចាប់កាន់ដៃករុណា។ ករុណាសំលឹងមើលមុខរបស់នីតា ឃើញទឹកមុខនីតា ដូចជាចង់យំ នាងក៏នៅស្ងៀម។ នីតានឹកក្នុងចិត្ត "ហ៊ឺ៎ៗៗ ធ្វើមុខ បែបនេះ ពិតជា បានផលមែន"។

- នីតា : ក្លឹបរបស់យើងពិតជាត្រូវការមនុស្សខ្លាំងណាស់ បើមិនគ្រប់ចំនួន កំណត់ទេនោះ លោកនាយកនឹងមិនព្រមទទួលស្គាល់ក្លឹបរបស់ពួកយើង ជាផ្លូវការនោះទេ។

នីតានិយាយដូចជាចង់រលីងរលោងទឹកភ្នែក។

- នីតា : តាំងពីតូចមក ខ្ញុំចូលចិត្តអានរឿងស៊ើបអង្កេតខ្លាំងណាស់ ជាពិសេស រឿងរបស់អ្នកស្រី Agatha Christie និង លោក Arthur Conan។ ខ្ញុំតែងតែកោតសរសើរការវិភាគរកហេតុផល របស់តួអង្គ Sherlock Holmes។ ខ្ញុំតែងតែស្រមៃថា ចង់ក្លាយជាអ្នកស៊ើបអង្កេតដ៏អស្ចារ្យម្នាក់។ ខ្ញុំចង់បង្កើត

ក្លឹបអ្នកស៊ើបអង្កេត ដើម្បីជួយដោះស្រាយការងារផ្សេងៗរបស់មនុស្ស នៅក្នុងសង្គមច្របូកច្របល់របស់យើងនេះ។ ខ្ញុំចង់ជួយ រកយុត្តិធម៌អោយជនរងគ្រោះទាំងឡាយ។

ករុណាសំលឹងមើលមុខរបស់នីតា។ នាងមិននឹកស្មានថាកូនអ្នកមាន ដូចជានីតា ចេះចង់ស្វែងរកយុត្តិធម៌ សំរាប់ជនរងគ្រោះនឹងអំពើអយុត្តិធម៌ ទាល់តែសោះហើយ។ នាងនឹកស្ញើចដល់ទឹកចិត្តរបស់នីតា ប៉ុន្តែការនិយាយស្តីរបស់នីតា របៀបដូចជាតួអង្គ កំពុងសំដែងល្ខោនដ៏កំសត់ម្នាក់នោះ ធ្វើអោយករុណាចេះតែចង់សើច។ ទីបំផុត នាង ទប់សំណើចមិនបាន ក៏សើចចេញមកយ៉ាងក្អាកក្អាយ។

នីតាមើលមុខករុណា។ នាងមិនយល់សោះថា ហេតុអ្វីបានជាករុណាសើច។

- នីតា : ម៉េចបានជាឯងសើច?

- ករុណា : គឺមកពីឯងនិយាយ ដូចជាតួក្នុងល្ខោនពេកហ្នឹងណាំ។

នីតាមើលមុខរបស់ករុណាហើយ នាងក៏ផ្ទុះសំណើចដែរ។ អ្នកទាំងពីរ បែរជា ក្លាយជាមិត្តនឹងគ្នាតាំងពីថ្ងៃចូលរៀនដំបូងនៅវិទ្យាល័យ "ហៃរ្យនម៉ា"។

- នីតា : ឯងចាំនៅទីនេះ មួយភ្លែតសិនហើយ! ខ្ញុំទៅហៅសមាជិកផ្សេងទៀត របស់ក្លឹបយើងសិន។

"ក្លឹបយើង?" ករុណាមិនទាន់ទាំងឆ្លើយប្រាប់ថា យល់ព្រមចូលក្លឹបនេះផង តែ នីតាបែរជាសំរេចចិត្តថា នាងជាសមាជិករបស់ក្លឹបនេះបាត់ទៅហើយ។ ករុណាហួសចិត្ត ហើយនឹកគិតថា សមាជិកផ្សេងទៀតរបស់ក្លឹបនេះ ប្រហែលជាមានចរិកដូចជានីតាដែរ ពូកែនិយាយដូចជាតួល្ខោន ហើយពូកែញញឹមដូចជាតួកំប្លែង។ ករុណាដើរ ទៅជិតបង្អួច ឃើញយុវជនមួយក្រុម

កំពុងលេងបាល់ទាត់។ មានសំលេងស្រែកហ៊ោ យ៉ាងខ្លាំង ដោយសារតែមានសិស្សប្រុសម្នាក់ទាត់ចូលមួយគ្រាប់។ ករុណាសំលឹង មើលទៅសិស្សប្រុសម្នាក់នោះ។ គេយកកន្សែង ពោះគោមកជូតញើសចេញ ហើយងើបមុខឡើង។ ករុណា មានអារម្មណ៍ថា បេះដូងរបស់នាងលោតញាប់ខុសធម្មតា។ មនុស្សម្នាក់នេះ នាងធ្លាប់ឃើញ ហើយធ្លាប់ជួបនៅទីណាម្តង។ តាំងតែពីថ្ងៃដែលនាងជួបគេមក រូបរបស់គេជិតជាប់នៅក្នុង ខួរក្បាល របស់នាងជានិច្ច។ ករុណា យកដៃស្តាំខ្ទប់មាត់របស់នាង និងដៃម្ខាងទៀតស្ទាបបេះដូង។

ឱុកដាក់ៗៗៗៗៗៗៗៗៗៗៗ......... "គេ គឺ... គេ គឺ..."

## វគ្គទី ២

មកដល់ផ្ទះ ករុណាបើកទ្វារចូលក្នុងផ្ទះ ឃើញបងស្រីនាងកំពុងតែអង្គុយវាយ កុំព្យូទ័រ។

- ករុណា : បងរី អត់ទៅមហាវិទ្យាល័យទើរ ថ្ងៃនេះ?
- ដារី : អត់ទេ... ថ្ងៃនេះ គ្រូបងរវល់ មិនបានមកបង្រៀនទេ។

ករុណាដើរទៅជិតតុធ្វើការរបស់បងស្រីនាង។

- ករុណា : បងកំពុងសរសេររឿងអ្វីហ្នឹង?
- ដារី : រឿងថ្មី។

ដារីដកដៃចេញពីកុំព្យូទ័រ ហើយយកដៃទ្រចង្ការ សំលឹងមើលទៅមុខប្អូនស្រី របស់ខ្លួន។

- ដារី ៖ និយាយតាមត្រង់ចុះ បងគ្មានជំនឿចិត្តនឹង អាចសរសេររឿងថ្មីនេះ បានទេ? សូម្បីតែតួអង្គ បងរកនឹកមិនឃើញផង តើអោយបងរកនឹកសរសេរ សាច់រឿងយ៉ាងម៉េចទៅ?
- ករុណា ៖ ហ៊ឺ... អស់សង្ឃឹមបែបនេះ មិនដូចជាបងសោះ។ បងស្រីខ្ញុំពូកែ ណាស់ ទើបតែចូលមហាវិទ្យាល័យឆ្នាំទីមួយសោះ ក៏បានបោះពុម្ពរឿងជាច្រើនរឿងទៅហើយ ហើយសុទ្ធតែទទួលបានការគាំទ្រពីអ្នកអានជា យុវវ័យដូចជាខ្ញុំទៀតផង។
- ដារី ៖ មិនចាំបាច់មកបញ្ជោរបងទេ។ បើថា អ្នកអានជាយុវវ័យនោះ ក៏នឹង មានតែអូនឯងម្នាក់ហ្នឹង។ ហាស ហា...
- ដារី ៖ មែនហើយ... ម៉េចក៏អូនឆាប់ត្រលប់មកផ្ទះវិញម្ល៉េះ? ក្រែងមិនទាន់ ដល់ម៉ោងចេញពីរៀនឯណា?
- ករុណា ៖ ហ៊ឺ... មានរឿងស្មានមិនដល់ច្រើនណាស់កើតនៅសាលាថ្មីនោះ។

- ដារី : មានរឿងអ្វីទៅ?

ករុណាក៏រៀបរាប់តាំងពីរឿង ដែលនាងជួបនីតា និងបាន ក្លាយទៅជាសមាជិក របស់ក្លឹបអ្នកស៊ើបអង្កេត ដោយឥតមាន ព្រៀងទុក...

ដារីកាន់ខ្មៅដៃគោះលើតុ... តុក... តុក...តុក...

- ដារី : អូ៎ បងនឹកឃើញហើយ រឿងថ្មីរបស់បង គឺរឿង ក្លឹបអ្នកស៊ើបអង្កេត ។
- ករុណា : ហ្ន៎ា...

ករុណាភ្ញាក់ផ្អើលជាខ្លាំងនឹងការនឹកឃើញរបស់បងស្រីនាង ដែលមិនយល់ថា ក្លឹបនោះមានបញ្ហា បែរជាយល់ថា ក្លឹបនោះ គួរអោយចាប់អារម្មណ៍ទៅវិញ ។

- ដារី ៖ អរគុណប្អូនសំលាញ់ណាស់ ដែលជួយដល់ការងារបង។ បងទូរស័ព្ទទៅ ប្រាប់ប្រធានបងសិនថា ចំណងជើងរឿងថ្មីបងនឹកឃើញហើយ។

ករុណារកតែនិយាយឃាត់បងស្រីនាងមិនបាន។ ដារីទូរស័ព្ទទៅប្រធានរបស់នាង ទាំងញញឹមពព្រាយ។ ករុណានិយាយលែងចេញ ក៏នៅស្ងៀម។ ដារីនិយាយទូរស័ព្ទចប់ ក៏ត្រលប់មកនិយាយជាមួយនឹងករុណាវិញ។

- ដារី ៖ ចាប់ពីពេលនេះទៅ បើមានអ្វីកើតឡើងនៅ ក្លឹបនោះ កុំភ្លេចប្រាប់ បងផងណា៎។
- ករុណា ៖ តែខ្ញុំមិនគិតថា ខ្ញុំនឹងចូលជាសមាជិក របស់ក្លឹបគេនោះទេ។
- ដារី ៖ ហ្អ៎ា ថាម៉េចហ្នឹង? ក្រែងរឿងរកយុត្តិធម៌ អោយជនរងគ្រោះ គឺជាបំណងរបស់អូនឯង តាំងតែពីក្មេង

មកម្លេះ។ ពេលនេះ អូនអាចមាន ឱកាសជួយមនុស្ស បានហើយ ហេតុអ្វីមិនធ្វើនោះ?

- ករុណា : ប៉ុន្តែ វាមិនដូចជារឿងក្មេងលេងពេកទេដឹង...

បងស្រីនាងលែងស្តាប់នាងនិយាយទៀតហើយ។

ដាវីច្រៀងបណ្តើរ វាយកុំព្យូទ័រ យ៉ាងញាប់ដៃស្មេរបណ្តើរ។ នៅលើអេក្រង់ យើងឃើញមានចំណងជើងធំៗថា "ក្លឹបអ្នកស៊ើបអង្កេត"។ វគ្គទី១ ....

ឃើញបងស្រីនាងសើច ញញឹម បិទមាត់មិនជិតបែបនេះ ករុណាក៏ញញឹម។ នាងក៏ដើរចូលទៅបន្ទប់របស់នាង។ ដាក់សំពៀតលើតុរួច នាងគិតថា "យ៉ាងម៉េច ក៏យ៉ាងម៉េចទៅចុះ!"

ថ្ងៃទីពីរមកដល់ ករុណាឈានជើងចូលវិទ្យាល័យ "ហៃ្សនម៉ា" ជាថ្មីម្តងទៀត។ នាងញញឹម ហើយដើរចូលដោយលែងភ័យខ្លាចទៀតហើយ។ ជីវិតប្រៀបបីដូចជា ខ្សែភាពយន្ត រឿងផ្សងព្រេង មួយអ៊ីចឹង។ យើងមិនអាចនឹងដឹងថា នឹងមានរឿងអ្វីកើតឡើងខ្លះទេនៅពេលខាងមុខនោះ។ អ្វីដែលសំខាន់ គឺត្រូវតែ

រស់នៅអោយសប្បាយ គប្បីចំពោះខ្លួនឯងនៅវេលាបច្ចុប្បន្ននេះ ដើម្បីកុំអោយមានវិប្បដិសារីទៅ ដល់ថ្ងៃក្រោយទៀត។ ករុណាញញឹម "អាំ ឃ្លានេះ គឺជាឃ្លា នៅក្នុងសាច់រឿងមួយ របស់បងវីទេតើ"។ ករុណាប្រហែលជា អ្នកគាំទ្រធំជាងគេបំផុត របស់បងស្រីនាងហើយ។ នាងចូលចិត្តអានសាច់រឿង ដែលបងស្រីនាងសរសេរ ហើយចងចាំនូវឃ្លាទាំងឡាយ ដែលមានប្រយោជន៍ដល់នាងក្នុងការរស់នៅប្រចាំថ្ងៃរបស់នាង។ នាងតែងតែលួចកោតសរសើរដល់បងស្រីនាងថា ឆ្លាត ព្យាយាម និងពូកែគ្រប់យ៉ាង។ ប៉ុន្តែ នាងមិនដឹងទេថា បងស្រីនាងក៏តែងតែលួចកោតសរសើរនាងនៅក្នុងចិត្តរបស់គេដែរ។ ហើយប្រហែលជាបើគ្មានករុណាទេនោះ ដាវីក៏នឹងមិនចាប់ផ្តើមសរសេររឿងប្រលោមលោកនោះដែរ។ អាចនិយាយបានថា បើគ្មានអ្នកគាំទ្រដ៏វិសេសដូចជា ករុណា ទេនោះ ដាវីនឹងមិនអាចបញ្ចេញទេពកោសល្យរបស់នាងអស់ពីចិត្តនោះទេ។

ដាវីឈរមើលប្អូនស្រីចេញទៅសាលារៀន។ នាងញញឹម "សំណាងល្អណាំ ប្អូន សំលាញ់។ ក្លឹបអ្នកស៊ើបអង្កេតនេះ

ប្រហែលជាអាចនឹងជួយអោយអូន ឈប់មើល ស្រាលលើខ្លួនឯងទៀត ។ តស៊ូឡើងណា៎!"

ចប់ម៉ោងរៀន ករុណាដើរសំដៅទៅក្លឹបអ្នកស៊ើបអង្កេត ។ បើកទ្វារភ្លឹប នីតានៅឈរចាំមាត់ទ្វារ ញញឹមយ៉ាងស្រស់ ដាក់ករុណា ។

- នីតា : ឯងមកហើយរឺ? ខ្ញុំស្មានតែឯងនឹងមិនមកទៀតទេ?
- ករុណា : ចាស... គឺ...

នីតានិយាយព្រមទាំងធ្វើមុខដូចជាចង់យំ ។

- នីតា : ខ្ញុំរំភើបដល់ហើយ ។

នីតាកាន់ដៃករុណាជាប់ ហើយដឹកដៃនាងទៅក្នុងក្លឹប ។

- នីតា : នេះជាសមាជិកថ្មីរបស់ពួកយើង ករុណា ។

ករុណាសំលឹងមើលទៅសិស្សប្រុសពីរនាក់ ដែលឈរនៅចំពោះមុខនាង ស្រាប់តែ បេះដូងរបស់នាងលោតឌុកដាក់.....

- ករុណា : ហ្ហ៎ា... គឺ... វិជ្ជា... សិស្សពូកែគណិតលេខ១ទូទាំងប្រទេស ។
- វិជ្ជា : អ៊ូ... គណិតលេខ៣ ទេហ្ន៎?
- ករុណា : ខ្ញុំឈ្មោះ ករុណា មិនមែនឈ្មោះ គណិតលេខ ៣ ទេ ។
- វិជ្ជា : ដឹងហើយ គណិតលេខ៣ ។
- នីតា : អ៊ីចឹង បងធំ ស្គាល់ ករុណា ដែរហ្ន៎?
- ករុណា : បងធំ?
- នីតា : ហ្នឹងហើយ គឺបងធំ ។ គាត់ជាប្រធានរបស់ក្លឹបយើង ។

- ភក្តី : សួស្តី ខ្ញុំឈ្មោះភក្តី ហៅខ្ញុំថា បងតូច ក៏បាន... ហាសហា...

"នេះហ្ន៎... សុទ្ធតែជាសមាជិកក្លឹបអ្នកស៊ើបអង្កេត។ សុទ្ធតែមនុស្សចំលែកទាំង អស់ហ្នឹង។ ខ្ញុំគិតខុស រឺត្រូវទេ មកចូលក្នុងក្លឹបនេះ។" ករុណាគិតក្នុងចិត្ត។

- ករុណា : ចាស សួស្តី ខ្ញុំគឺ ករុណា។
- ភក្តី : គណិតលេខ ៣។ ខ្ញុំឧស្សាហ៍លឺបងធំនិយាយដែរ។
- ករុណា : ខ្ញុំ ករុណា មិនមែនគណិតលេខ៣ ទេ។
- នីតា : អូ៎ និយាយអ៊ីចឹង គណិតលេខ ៣ នោះ គឺបងធំ សំដៅទៅដល់ ករុណា ជាប់លេខ៣ ផ្នែកគណិតវិទ្យាទូទាំងប្រទេសនោះទេហ្ន៎? អ៎ា... ខ្ញុំក៏ធ្លាប់លឺដែរ។ ការពិត ករុណា គឺ គណិតលេខ៣ សោះ។

- ករុណា : ខ្ញុំឈ្មោះ ករុណា មិនមែនឈ្មោះថា គណិតលេខ៣ទេ។

ករុណាខំបញ្ជាក់ឈ្មោះរបស់នាងជាច្រើនដង តែមើលទៅសមាជិកក្នុងក្លឹបនេះ ដូចជាមិនចាប់អារម្មណ៍លើសំដីនាងសោះ។ នាងក៏បែរជាជាប់រហស្សនាមថា "គណិតលេខ៣" រហូតមកទៅវិញ។ ករុណាមិនសប្បាយចិត្តសោះ ដែលគេហៅនាងបែបនេះ។ ករុណាខឹងនឹងវិជ្ជាតាំងពីនាងជួបគេដំបូងម្ល៉េះ។ គេចូលចិត្តញញឹមបង្កប់ ដោយអាថ៌កំបាំង ហើយបន្ទាប់មក ហៅនាងថា គណិតលេខ ៣ តាំងពីថ្ងៃចែករង្វាន់ សិស្សពូកែទូទាំងប្រទេសមកម្ល៉េះ។ នាងមិនចង់ជួបមុខនឹងវិជ្ជាទៀតទេ។ ម្សិលមិញ ឃើញគេលេងបាល់នោះ ក៏ខំតាំងចិត្តថា ខ្លួនឯងស្រវាំងភ្នែកទេ។ តែមិននឹកស្មានថា ការពិត គឺវិជ្ជា មែន។ ហើយឥលូវនេះ គេក៏ជាប្រធានក្លឹបរបស់នាងទៀត។ រៀននៅសាលាជាមួយគ្នា ចូលរួមក្នុងក្លឹបតែមួយ នាងច្បាស់ជានឹងត្រូវប្រឈមមុខនឹងគេជា រៀងរាល់ថ្ងៃមិនខានទេ។

*និពន្ធដោយ លឹម សន្តិភាព*

រំពេចនោះ ទ្វារបន្ទប់របស់ក្លឹបអ្នកស៊ើបអង្កេតរបើកឡើង។ សិស្សស្រីម្នាក់ ខ្លួនញ័ររធំប្រប់ស្រែកសន្ធាប់ ៖

- ដានី ៖ មានរឿងធំហើយ។ លីនដា លីនដា... បាត់ខ្លួនហើយ។
- វិជ្ជា ៖ លីនដាបាត់ខ្លួន? ដានីច្បាស់ហើយមែនទេ?
- ដានី ៖ ចាស... ច្បាស់ណាស់។

វិជ្ជា ភក្តី និង នីតា មើលមុខគ្នា ហើយងក់ក្បាលដាក់គ្នា។ ពួកគេក៏រត់ចេញពីថ្នាក់ យ៉ាងលឿន។ ករុណាមិនយល់ថា ពួកគេទាំងបីចង់ធ្វើអីនោះទេ នាងឈររឆ្ងឹង។ មួយសន្ទុះ ស្រាប់តែវិជ្ជាមកអូសដៃករុណា។

- វិជ្ជា ៖ នៅឈរដល់ណាទៀត គណិតលេខ៣? តោះទៅ!
- ករុណា ៖ អេ៎ អុសខ្ញុំទៅណា? ... ខ្ញុំមិនមែនគណិតលេខ៣ទេ។ ខ្ញុំគឺករុណា...

## វគ្គទី ៣

បន្តិចក្រោយមក សមាជិកក្លឹបអ្នកស៊ើបអង្កេតទាំងបី មកដល់ផ្ទះរបស់លីនដា។ អូ៎ ភ្លេច នៅមាន *គណិតលេខ៣* សមាជិកថ្មីរបស់ក្លឹប ក៏មកដែរ។ **"ខ្ញុំឈ្មោះ ករុណា មិនមែនគណិតលេខ៣ ទេ"** ។ ដឹងហើយ ដឹងហើយ ...

នៅក្នុងបន្ទប់របស់លីនដា មាន ដានី សុខា សំណាង ចន្ទ្រា ម្តាយរបស់លីនដា និង នាយកសាលា "ហ៊ែរ្យនម៉ា" ។

នីតាកាន់កូនសៀវភៅ និងខ្មៅដៃមួយនៅនឹងដៃ កត់ត្រាអ្វីដែលមនុស្សនៅទីនោះ និយាយ។

- នាយកសាលា ៖ គ្រាន់តែលឺពី លោកគ្រូក្នុងថ្នាក់និយាយថា លីនដា មិនមករៀន ខ្ញុំក៏ប្រញាប់ទូរស័ព្ទមកសួរអ្នកបង ខ្លាចក្រែងលីនដា ឈឺថ្កាត់ អ្វីមិនអាចមករៀនបាន។
- ម្តាយលីនដា ៖ ចំលែកណាស់ កាលពីព្រឹកនោះ លីនដា មិនបានញ៉ាំអាហារ ពេលព្រឹកនោះទេ។ នាងនិយាយថា

នាងប្រញាប់ទៅសាលា ព្រោះ ម៉ោង ៦ និង៤៥នាទី ទៅហើយ។

- នាយកសាលា ៖ លីនដាជាសិស្សល្អប្រចាំសាលា។ គេមិនដែលអវត្តមាន ឥតច្បាប់នោះទេ។ គេជាសិស្សគោរពវិន័យសាលាល្អណាស់។ សូម្បីតែទៅ យឺតម្តងក៏មិនដែលដែរ។
- ដានី ៖ ម្សិលមិញនោះ ដាប្រាប់ថា ខ្ញុំមិនចាំបាច់មកទទួលដាទេ ដា អាចទៅខ្លួនឯងបាន។ ដូចនេះ ប្រហែលជាម៉ោង ៦ និង ៤០នាទី ខ្ញុំចេញពី ផ្ទះជាមួយនឹងតែកុងឡានរបស់ខ្ញុំ ទៅសាលារៀន។ ខ្ញុំស្មានតែដាទៅជាមួយនឹងសំណាងទេតើ។
- សំណាង ៖ អត់ទេ។ ព្រឹកមិញនេះ ខ្ញុំបានទៅទទួលចន្ទ្រា យើងទៅសាលារៀន ជាមួយនឹងគ្នាតាំងពីម៉ោង៦កន្លះព្រឹក។
- ដានី ៖ ថាម៉េច? សង្សារខ្លួនឯង មិនមកទទួល បែរជាទៅទទួលស្រីផ្សេង។

- ចន្ទ្រា : លីនដានៅជាសង្សាររបស់បងសំណាងរឺ? ទេ គាត់ប្រាប់ខ្ញុំថា ពួកគាត់ បែកគ្នាហើយ។ បងសំណាង ប្រាប់មកមើល៍ នេះបានន័យថាម៉េច?
- សំណាង : អឺ... គឺ...
- ដានី : នេះច្បាស់ជារឿង ជើងមួយជាន់ទូកពីរហើយ មែនទេ? មនុស្សប្រុស អាក្រក់មែន។ បើលីនដា ដឹង រឿងនេះ ចាំមើលតើសំណាងឯងរួចខ្លួនតាម របៀបណា?

សំណាងនៅស្ងៀម មិនមាននិយាយអ្វីទៀត នៅពេលដានីនិយាយចំចំណុច របស់គេនោះ។

- ម្ដាយលីនដា : សុខា ព្រឹកមិញនេះ ក្មួយអត់បានមក ទទួលកូនដាទេហ្អេ៎?
- សុខា : បាទ អត់ទេ។ ព្រឹកមិញនេះ ប្រហែលជាម៉ោង ៦ជាង ពួកម៉ាកខ្ញុំ វាហៅទៅគុយទាវជាមួយពួកវា។ ដល់ម៉ោង ៧គត់ ខ្ញុំទៅដល់សាលា "ហ៊ែរ្សនម៉ា"។

- វិជ្ជា : ពួកម៉ាកទៅគុយទាវជាមួយសុខា សុទ្ធតែប្រុស ទាំងអស់ហ្មែ?
- សុខា : មែនហើយ សុទ្ធតែប្រុសទាំងអស់ ។

ភក្តីស្រែករបៀបដូចជាភ្ញាក់ផ្អើល ។

- ភក្តី : និយាយអ៊ីចឹង ថ្ងៃនេះ ម៉េចក៏សុខា និង សំណាង ពាក់អាវដូចគ្នាម្ល៉េះ?

កំពុងតែនិយាយរឿងបាត់ខ្លួនលីនដា បែរជាភក្តីនិយាយអំពីរឿងម៉ូតអាវ អីណាអីនោះទៅវិញ ធ្វើអោយគ្រប់គ្នាឆ្ងល់ បែរទៅមើល សុខា និងសំណាង ទាំងពីរនាក់ ។

- សំណាង : អាវនេះជាអាវទើបនឹងចេញថ្មី នៅហាង "ញូខូលិក" ខ្ញុំទិញវា កាលពីម្សិលមិញនេះឯង ។

- សុខា : មែនហើយ។ ខ្ញុំក៏ទើបទិញកាលពីម្សិលមិញ ហើយទើបនឹងពាក់ ព្រឹកមិញនេះឯង។

ភក្តី និងវិជ្ជាមើលមុខគ្នា ហាក់ដូចជានិយាយភាសា សំងាត់អ្វីម្យ៉ាងជាមួយ នឹងគ្នា។

- ម្តាយលីនដា : កូនដា មិនទៅជាមួយនឹងដានី ហើយក៏មិនទៅជាមួយ នឹងសំណាង ចុះកូនដា ទៅជាមួយនឹងនរណា? លីនដា មិនអាចនឹងទៅជាមួយនឹងមនុស្សមិនស្គាល់គ្នានោះទេ។ ហើយថ្មីៗនេះ ខ្ញុំដូចជាមិនឃើញកូនដា និយាយពីរឿងមិត្តថ្មីរបស់នាងប្រាប់ខ្ញុំដែរ។ កូនដា តែងតែប្រាប់ខ្ញុំជានិច្ច ពីរឿងនៅសាលារៀនរបស់គេ ដូចជារឿងគ្រូបង្រៀន រឿងមិត្តរួមថ្នាក់ នៅមានរឿងក្លឹបចំលែក នៅសាលារៀនរបស់នាង... នាងថាក្រៅពីមាន ក្លឹបគីមី ក្លឹបភ្លេង ហើយ នៅមានក្លឹបអីទេ??? នៅចុងៗមាត់ខ្ញុំ។

- ករុណា ៖ គឺ **ក្លឹបអ្នកស៊ើបអង្កេត** ។
- ម្ដាយលីនដា ៖ ហ្នឹងហើយ។ ពេលលឺរឿងនេះដំបូង ខ្ញុំក៏ចង់សើចដែរ។ ហេតុអ្វីលោកនាយកសាលា បណ្ដោយអោយសិស្សបើក**ក្លឹបអ្នកស៊ើបអង្កេត**? វាដូចជានៅក្នុងខ្សែភាពយន្តផ្នែកស៊ើបអង្កេតអ៊ីចឹង។
- ករុណា ៖ មែនហ្នឹងហើយ ។ ខ្ញុំក៏ឆ្ងល់ដូចគ្នា ។

លោកនាយកសាលាមើលទៅមុខ នីតា វិជ្ជា និងភក្ដី ។ ពួកគេទាំងបីញញឹម ដាក់នាយកសាលា។ នីតាមើលទៅមុខរបស់ករុណា ដែលកំពុងតែនិយាយចំអក ដល់ក្រុមក្លឹប អ្នកស៊ើបអង្កេត ដែលការពិតនោះ ករុណា ក៏ជាសមាជិកម្នាក់នៅក្នុងក្លឹបនោះដែរ ។

- នាយកសាលា ៖ ក៏ព្រោះតែ... អឺ...
- វិជ្ជា ៖ ក៏ព្រោះតែ ក្នុងក្លឹបនោះ សមាជិកនិមួយៗ សុទ្ធតែចង់ក្លាយខ្លួនជា

មេធាវីការពារយុត្តិធម៌អោយជនរងគ្រោះ។ ដោយសារតែពួកគេនៅជាសិស្ស វិទ្យាល័យនៅឡើយ ពួកគេចង់ហាត់រៀនវិភាគរឿងក្ដីផ្សេងៗទៅតាមផ្លូវ ច្បាប់ ជាជាងចំណាយពេលដើរលេងអត់ប្រយោជន៍។

- នាយកសាលា : ថាអ៊ីចឹងក៏បានដែរ។

នាយកសាលាបានតែញញឹម តែការពិត មិនមែនដោយសារតែមូលហេតុនេះ ទាំងស្រុងនោះទេ។ វាមានមូលហេតុចាំបាច់ផ្សេងមួយទៀត ដែលនាយកសាលា មិនអាចនឹងប្រកែកក្នុងការបង្កើតក្លឹបនេះឡើង។

- ម្ដាយលីនដា : អូ៎ មែនហើយ និយាយអ៊ីចឹង មីងដូចជាមិនដែលឃើញ ក្មួយទាំងបួនពីមុនមកសោះ។ ក្មួយទាំងបួនជាមិត្តរបស់កូនដា ដែរហ្ន៎?

- នីតា ៖ ចាស ខ្ញុំជាមិត្តរួមថ្នាក់របស់ដា។ ហើយពួកយើងទាំងបួន គឺជា សមាជិករបស់ក្លឹបអ្នកស៊ើបអង្កេត។

ម្តាយរបស់លីនដាដូចជាភ្ញាក់ផ្អើលបន្តិច ដែលមុននេះ គាត់បាននិយាយបង្ហាប់ ក្លឹបនេះ នៅពីមុខសមាជិក របស់ក្លឹបទាំងអស់គ្នា។

- វិជ្ជា ៖ ហើយម្នាក់ ដែលយល់ស្របថា ក្លឹបរបស់យើងជាក្លឹបចំលែកនេះ ក៏ជាសមាជិកក្លឹបនេះដែរ។

វិជ្ជាចង្អុលទៅករុណា។ ករុណាលានអណ្តាតដាក់វិជ្ជា។ វិជ្ជាលាតអណ្តាតដាក់ ករុណាវិញ។

- នាយកសាលា ៖ និយាយអ៊ីចឹង អ្នកបង គិតថា គួរប្តឹងប៉ូលីស ដែរទេ?

ករុណាសំលឹងទៅមើលមុខរបស់សំណាងយ៉ាងចំលែក។ បន្ទាប់នេះ មាន ម៉ាស៊ីនត្រជាក់ រហូតដល់ធ្វើអោយករុណាមានអារម្មណ៍ថា នាងកំពុងតែឈរនៅប៉ូលខាងជើង ទៅហើយ។ ចុះហេតុអ្វីបានជាសំណាងយកកន្សែងជូតញើសរបស់គេជាញឹកញាប់បែបនេះទៅវិញ។

ដានី ជាមិត្តជិតស្និទ្ធនឹងលីនដា។ សំណាងជាសង្សាររបស់លីនដា។ ចន្ទ្រាជា សង្សាររបស់សំណាង។ សុខា ជាបងជីដូនមួយរបស់លីនដា។ បាត់ប្អូនស្រីម្នាក់មួយ ទាំងមូលតែទឹកមុខសុខា មិនបញ្ចាក់ថា គេដូចជាព្រួយចិត្តអ្វីម្យ៉ាងទាល់តែសោះ។ ករុណាដើរទៅជិតសុខា នាងក្រលេកឃើញសុខាក្តាប់ដៃ ដូចជាលាក់បាំងអ្វីនៅ ក្នុងដៃ។ រំពេចនោះស្រាប់តែឃើញនីតាគ្រេចជើងដួលទៅលើសុខា ដោយសារតែជាសភាវគតិ សុខាប្រញាប់លាដៃទប់នីតាកុំអោយនាងដួល។ ឃើញមានស្នាមធ្មេញខាំនៅ លើចំហៀងបាតដៃរបស់សុខា។ រំពេចនោះសុខា ប្រញាប់លាក់ដៃរបស់គេវិញ។

*និពន្ធដោយ លឹម សន្តិភាព*

កររុណានឹកក្នុងចិត្ត "លីនដាមិនដែលទៅជាមួយនឹងនរណា ដែលគេមិនស្គាល់ ទេពីមុនមកនោះ។ ព្រឹកមិញនេះ នាងមិន ទៅជាមួយនឹងដានី នាងគួរតែនឹងទៅ ជាមួយនឹងសំណាង បើមិនអ៊ុចឹង គឺទៅជាមួយនឹងសុខា។ ហេតុអ្វីក៏សំណាង ហាក់ដូចជាប្លែកខ្លាំងម្លេះ? ប្រៀបដូចជាមនុស្សធ្វើកំហុស អ្វីម្យ៉ាងធ្ងន់ជាលើកទី១។ សំណាងធ្លាប់មកទទួលលីនដា តែព្រឹកនេះ គេបែរជាទៅទទួលចន្ទ្រា តាំងពីម៉ោង ៦កន្លះ។ រីមួយ គេគ្រាន់តែបង្កើតភស្តុតាងថា គេនៅជាមួយនឹងមនុស្សម្នាក់ផ្សេង ទៀត ក្នុងពេលដែល លីនដា បាត់ខ្លួននោះ។ មនុស្ស ដែលគួរអោយសង្ស័យជាងគេ នោះ គឺមានតែ..."។

- វិជ្ជា : ប្រសិនបើសុខា មិនប្រាប់ពួកយើងថា លីនដា នៅទីណា ក្នុងពេលនេះ ទេនោះ ប្រហែលជា ពួកយើងគួរតែប្តឹងប៉ូលីសមែនហើយ។

ពេលនោះ សុខា ភ្ញាក់ផ្អើលជាខ្លាំង។ គ្រប់គ្នា សំលឹង ទៅមើលវិជ្ជា។ បន្តិចមក ទើប សុខាសើច។

- សុខា : បានន័យថាម៉េចហ្នឹង វិជ្ជា? កុំអាងតែឯងជាសិស្ស ពូកែទូទាំងប្រទេស ហើយដើរចោទគេ ចោទឯងថា គេធ្វើអំពើមិនល្អនោះ។ គ្មាននរណា គេចេះតែជឿ លើសំដីឯងរហូតនោះទេ។ មានភស្តុតាងអី មកចោទ យើង ថា ពួកយើងចាប់ជីវិតខ្លួនអូនដានោះ?
- វិជ្ជា : ហ្ហា... ខ្ញុំមិនបាននិយាយថា សុខាចាប់ជីវិត ខ្លួនលីនដាទេ។ ម៉េចក៏សុខា និយាយពាក្យនេះ ចេញមកបាន? រឺមួយក៏សុខាពិតជាចាប់ខ្លួនលីនដាមែន?

សុខាភ្ញាក់ខ្លួននឹងសំដីរបស់វិជ្ជា ធ្វើអោយមនុស្សទាំងអស់ នៅក្នុងបន្ទប់មើល ទៅមុខរបស់សុខាគ្រប់គ្នា។

- នីតា : អីយ៉ា ដានី ខ្សែដៃរបស់ឯង ស្អាតណាស់ ធ្វើខ្លួនឯង មែនទេ?

- ដានី : មែនហើយ។ ខ្ញុំបានទិញអំបោះមកក្រង ជាខ្សែដៃខ្លួនឯង ហើយខ្ញុំបាន អោយមួយខ្សែទៀត ទៅលីនដាកាលពីម្សិលមិញ។
- នីតា : ដូចគ្នាអ៊ីចឹងហ្ន៎?
- ដានី : គឺដូចគ្នាអ៊ីចឹង។
- នីតា : បើអ៊ីចឹង បានន័យថា ម៉ូតនេះ ទិញនៅផ្សារ មិនបានទេ មែនទេ?
- ដានី : គ្មានទេ។ វាជាម៉ូត ខ្ញុំគិតឃើញខ្លួនឯង មិនបាន មើលនៅក្នុងកាតាឡុក អីនោះទេ។ ខ្ញុំគិតថា រកទិញ មិនបានទេ។ ចុះម៉េចក៏សុខា មានអាមួយនេះ ដែរ នៅក្នុងហោប៉ៅខោរបស់សុខា?

គ្រប់គ្នាក៏សំលឹងមើលទៅសុខា។ សុខាភ្ញាក់ផ្អើលរឹតតែខ្លាំង។

- នីតា : អំបាញ់មិញនេះ ខ្ញុំបានខ្សែដៃនេះនៅចុង ហោប៉ៅខោរបស់សុខា ខ្ញុំក៏ធ្វើជាដួលទៅលើសុខា ដើម្បី

ឆក់យកវាចេញមកមើល។ ខ្ញុំក៏មិននឹកស្មានថា វាដូចបេះបិតទៅនឹងរបស់ដានីដែរ។

- វិជ្ជា : ដានី លីនដា ចូលចិត្តក្រែមលាបមាត់ ពណ៌ឈាមជ្រូក ភ្លឺណាស់ មែនទេ?
- ដានី : មែនហើយ។ តែអាដាប្លែកណាស់។
- វិជ្ជា : ហេតុអ្វី?
- ដានី : អាដា ចូលចិត្តយកពណ៌លាបភ្នែកពណ៌មាសមកលាបលើ បបូរមាត់បន្ថែមទៀត។ ដាថា ធ្វើអ៊ីចឹងទើបបបូរមាត់កាន់តែភ្លឺស្អាត។
- វិជ្ជា : ភ្លឺដូចបែបនេះរឺ?

វិជ្ជាចង្អុលទៅលើខ្នងអាវរបស់សុខា ដែលមានជាប់ស្នាមបបូរមាត់របស់ លីនដា។

- ដានី : មែនហើយ គឺបែបនេះ។

លើកនេះ សុខាកាន់តែកុនខ្លួន មែនទែន។ នេះប្រហែលជាពេលដែល លីនដា និងសុខាប្រតាយប្រតប់គ្នា លីនដា បានលួចដាក់ខ្សែដៃរបស់នាងនៅហោប៉ៅរបស់សុខា ប្រហែលជានាងចង់ផ្ដល់សញ្ញាដល់ដានីថា នាងនៅជាមួយនរណា។ ដើម្បីកុំអោយសុខា មើលឃើញស្នាមក្រែមរបស់នាង នាងបានផ្ដិតបបូរមាត់នៅនឹងខ្នងអាវរបស់សុខា។ ហើយនាងគិតថា យ៉ាងហោចណាស់ ក៏មានមនុស្សម្នាក់ស្គាល់ពីទំលាប់ចំលែករបស់នាងដែរក្នុងការលាបក្រែមមាត់នេះ។

- វិជ្ជា : អាវរបស់សុខាទើបតែចេញកាលពីម្សិលមិញ ហើយសុខា ទើបនឹងពាក់ថ្ងៃនេះ ម៉េចក៏មានស្នាមបបូរមាត់លីនដា ជាប់នៅលើនោះ? ចុះស្នាមខាំនៅលើដៃរបស់សុខានេះ គឺវានៅថ្មី១ណាស់។ រីក៏ព្រឹកមិញនៅសាលា ហ្វៃទ្បូនម៉ា មានស្រីណាម្នាក់ខាំសុខា។ បើតាមទូរស័ព្ទ ខ្ញុំទទួលបានអំបាញ់មិញនេះ គឺសុខាលេងល្បែងចាញ់អស់ជាច្រើន ហើយ ជំពាក់គេទៀត

ផង។ ចំនួន ដែលសុខា ជំពាក់គេនេះ វាមិនហួសពីសមត្ថភាព សងរបស់សិស្សវិទ្យាល័យពេកទេវី? ប្រសិនបើសុខា មិនព្រមប្រាប់ពីកន្លែងលាក់ខ្លួនរបស់លីនដាទេនោះ ពួកយើងនឹងទុករឿងនេះ អោយប៉ូលីសដោះស្រាយ ហើយនឹងប្រាប់ពួកគេថា ជនសង្ស័យបំផុតគឺជាសុខានេះឯង។ សុខាគិតថា នឹងមានផ្លូវអាចរួចខ្លួនទេ?

សុខា ស្លុតអារម្មណ៍ ហើយក៏លុតជង្គង់គ្រីបនៅ ពីមុខម្តាយលីនដា។

- សុខា : អ្នកមីង សុំទោសផង! ខ្ញុំគ្មានចេតនានឹង ធ្វើបាបអូនដាទេ។ ខ្ញុំគ្រាន់តែ ចង់បានលុយខ្លះ យកទៅសងគេប៉ុណ្ណោះ។ ប្រសិនបើលោកប៉ាដឹងថា ខ្ញុំលេងល្បែង ហើយជំពាក់គេច្រើនយ៉ាងនេះ គាត់ច្បាស់ជានឹងសំលាប់ខ្ញុំមិន ខានទេ។

ម្តាយរបស់លីនដាស្រាប់តែស្រក់ទឹកភ្នែក។ គាត់យល់សប្តិ៍ក៏នឹកស្មានមិន ដល់ថាក្មួយប្រុសគាត់ហ៊ានធ្វើរបៀបនេះដែរ។

- ម្តាយលីនដា : សុខា មីងស្រលាញ់ឯង ដូចជាកូនមីងបង្កើត។ មានរឿងអ្វី ម៉េចមិនមក ពិភាក្សាជាមួយនឹងមីង បែរជាទៅធ្វើបាបប្អូនស្រីរបស់ឯងទៅវិញ។ ឯងក៏ដឹងហើយថា លីនដា ស្រលាញ់ឯងដូចជាបងប្រុសបង្កើតរបស់ វាអ៊ីចឹង។ តើវាខកចិត្តប៉ុណ្ណា នៅពេលមនុស្ស ដែលវាទុកចិត្តបំផុតក្បត់ នឹងវានោះ?
- សុខា : គឺ....
- ម្តាយលីនដា : អរគុណ ក្មួយៗទាំងអស់គ្នាហើយ។ ខ្ញុំគិតថា ខ្ញុំមិន ចង់អោយរឿងនេះបែកខ្ចាយនោះទេ។ សុខា ជាក្មួយបង្កើតរបស់ខ្ញុំ។ ប្រសិនបើរឿងនេះបែកទៅនោះ អនាគតរបស់ សុខា ច្បាស់ជារលាយមិនខានទេ ហើយប៉ារបស់សុខា ច្បាស់ជានឹងកាត់កាល

សុខាចោល។ ខ្ញុំស្គាល់បងប្រុសខ្ញុំច្បាស់ណាស់។ គាត់មិនយល់ញាតិ ឃ្លាតច្បាប់នោះទេ។

- លោកនាយកសាលា : មិនអីទេ ខ្ញុំក៏មិនចង់អោយអនាគតក្មេងម្នាក់ ដែល ទើបតែអាយុប៉ុណ្ណេះរលាយបាត់ទៅដែរ។ ខ្ញុំនឹងជួយលាក់រឿងនេះ។ ប៉ុន្តែដើម្បីរក្សាសុវត្ថិភាពសាលារបស់ខ្ញុំ ខ្ញុំមិនអាចនឹងទុកអោយសុខា ជាសិស្ស នៅសាលា ហ្វៃរ្សនម៉ាទៀតនោះទេ។
- ម្ដាយលីនដា : មិនអីទេ។ ខ្ញុំនឹងនិយាយជាមួយបងប្រុសខ្ញុំអោយបញ្ជូន សុខាទៅរៀននៅក្រៅប្រទេសដើម្បីអោយគ្នាកែចារិកឈប់លេងល្បែង នេះ។

ក្រោយមក សុខា ក៏ប្រាប់ពីកន្លែងលាក់លីនដា។ "ហ៊ឺ... ចិត្តមនុស្សស្មាន ពិបាកមែន។ មនុស្ស ដែលយើងទុកចិត្ត បំផុតក៏អាចជាអ្នកក្បត់យើងបានដែរ"។ ករុណាគិតបណ្ដើរ ដើរតាមនីតា វិជ្ជា និងភក្តី ចូលក្នុងឡានបណ្ដើរ។ នាងឈរផ្ទឹង

ហើយសំលឹងទៅមើល សមាជិកក្លឹបអ្នកស៊ើបអង្កេត ទាំងបីនាក់នោះ ។

"ហេតុអ្វី ក៏ពួកគេទាំងបីដូចជាស៊ីសង្វាក់គ្នាបានល្អម្ល៉េះ ក្នុងពេលរកភស្តុតាង សំរាប់រឿងក្តីមួយនេះ។ រីមួយក៏ដូចជានីតា និយាយមែនថា គេធ្លាប់ទាំងបានជួយ ប៉ូលីសក្នុងការស្វែងរកភស្តុតាងក្នុងរឿងក្តីពីមុនមកមែន" ករុណានឹកក្នុងចិត្ត ។

ករុណាមិនអស់ចិត្តសោះ ។ អំបាញ់មិញ នាងនឹកស្មានតែសំណាង ដែលបែកញើសស្រោក់នោះ មានជាប់ទាក់ទងក្នុងរឿងបាត់ខ្លួនរបស់លីនដាដែរ ។ តែមិននឹក ស្មានថាគេបែកញើស ព្រោះតែខ្លាចចន្ទ្រារករឿងគេ នៅពេលគេចេញពីផ្ទះលីនដា ។ គេភ័យនឹងរឿង បែកការជើងមួយជាន់ទូកពីររបស់គេសោះ ។ នាងសង្ស័យសុខាដែរ តែមិនបានរកឃើញភស្តុតាងច្រើនយ៉ាងនេះនៅលើខ្លួនសុខានោះទេ ។

"គិតទៅនៅមានរឿងច្រើនណាស់ ដែលខ្ញុំត្រូវរៀន ពីសមាជិកក្លឹបអ្នកស៊ើបអង្កេត នេះ" ករុណានឹកក្នុងចិត្ត ។

នាងញញឹម ហើយចូលទៅអង្គុយនៅក្នុងឡាន។ រំពេចនោះស្រាប់តែ វិជ្ជា វាយក្បាលនាងស្រាលៗ។

- វិជ្ជា : ញញឹមអី *គណិតលេខ៣* ?
- ករុណា : គ្មានអីទេ។ ហើយឈប់ហៅខ្ញុំ *គណិតលេខ៣* ទៀតទៅ។
- នីតា : បងធំ យើងគិតទៅញ៉ាំអីនៅឯណា ដើម្បីជប់លៀងការងារបានល្អ របស់យើងថ្ងៃនេះ?
- ភក្តី : ទៅហាងចាស់របស់ពួកយើងទៅ។
- នីតា : អូខេ។
- ភក្តី : *គណិតលេខ៣* ទៅជាមួយពួកយើងដែរ អូខេ?
- ករុណា : អឺ... ចាំខ្ញុំទូរស័ព្ទទៅផ្ទះសិន។
- ភក្តី : អេំ ផ្ទុះ *គណិតលេខ៣* តឹងតែងម្ល៉េះ គ្រាន់តែញ៉ាំបាយក្រៅមិនបាន នោះ។
- ករុណា : បងស្រីខ្ញុំ គាត់នៅតែម្នាក់ឯង ខ្លាចគាត់អផ្សុក។
- នីតា : ហៅបងស្រី *គណិតលេខ៣* ឯង មកដែរមក!

*និពន្ធដោយ លឹម សន្តិភាព*

- ករុណា : ចាំខ្ញុំសួរគាត់សិន។ អេ៎ ឈប់សិន។ តើអ្នកទាំងអស់អាចឈប់ហៅ ខ្ញុំថា *គណិតលេខ៣* បានទេ? ខ្ញុំករុណា មិនមែនគណិតលេខ៣ ទេ។

ហាសហា...

សំលេងសំណើចយ៉ាងក្អាកក្អាយលាន់ចេញពីក្នុងរថយន្តរបស់ក្លឹប អ្នកស៊ើបអង្កេតដ៏វ័យក្មេងរបស់ពួកយើង។

**សមាគមសេរីភាព**

**LIBERTY ASSOCIATION**

សមាគម សេរីភាព (Liberty Association) បង្កើតឡើងចាប់ពីឆ្នាំ 2009 ក្នុងគោលបំណង ជួយលើកកំពស់វិស័យអក្សរសាស្ត្រ និងអក្សរសិល្ប៍ នៅក្នុងប្រទេសកម្ពុជា។

ក្នុងពេលបច្ចុប្បន្ន សមាគមបង្កើត គេហទំព័រសៀវភៅជាភាសាខ្មែរ សំរាប់អ្នកអានជនជាតិខ្មែរ ដែលនៅទូទាំងពិភពលោក។

ទំនាក់ទំនង ៖ **cambocanada@gmail.com**